ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

# លិខិតជូនពរ

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាខួបកំណើតគម្រប់ ៨៣ឆ្នាំ ឈានចូល ៨៤ឆ្នាំ
## ( ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៣៤ ~ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ )

**សម្តេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាខួបកំណើតគម្រប់ ៨៣ឆ្នាំ ឈានចូល ៨៤ឆ្នាំ របស់សម្តេចជាទីគោរព ក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញ និងរូបខ្ញុំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ខ្ញុំមានកិត្តិយសនិងបីតិសោមនស្សរីករាយ សូមគោរពជូនសព្ទសាធុការពរជ័យបវរសួស្តីមហាប្រសើរ សូមសម្តេចអគ្គមហាពញាចក្រី ប្រកបដោយសុខភាពល្អប្រសើរ មានកម្លាំងមាំមួន អាយុយឺនយូរ ប្រាជ្ញាឈ្លាសវៃ ដើម្បីសម្រេចបាននូវមហាជោគជ័យដ៏ត្រចះត្រចង់ថ្មីៗថែមទៀតក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំតែងតែចងចាំជានិច្ចក្នុងដួងចិត្ត នូវសកម្មភាពប្រកបដោយឧត្តមគតិស្នេហាជាតិមាតុភូមិ និងគតិបណ្ឌិតរបស់សម្តេចអគ្គមហាពញាចក្រី ក្នុងការរំដោះប្រជាជនខ្មែរពីរបបប្រល័យពូជសាសន៍ ជួយដឹកនាំជោគវាសនាជាតិមាតុភូមិ ស្វែងរកការផ្សះផ្សាបង្រួបបង្រួមជាតិឱ្យមានសុខសន្តិភាព និងការអភិវឌ្ឍសង្គមជាតិលើគ្រប់វិស័យ ជាពិសេសការកសាងនីតិរដ្ឋនៅកម្ពុជា។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ព្រមទាំងទេវតាគ្រប់ទិសទី មានទេវតាឆ្នាំថ្មីព្រះនាម **កិមិរាទេវី** តាមជួយជ្រោមជ្រែងបីបាច់ថែរក្សាការពារ សម្តេចអគ្គមហា-ពញាចក្រី លោកជំទាវ បុត្រា បុត្រី ព្រមទាំងចៅៗទាំងអស់ សូមបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាពញាចក្រី** មេត្តាទទួលនូវអភិវន្ទនកិច្ចប្រកបដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។ ៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**អ៊ុម សារិទ្ធ**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh